**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសាធារណការ និងដឹកជញ្ជូន**
លេខៈ ០០៥ ឥ.ហ.សក

រាជធានីភ្នំពេញ, ថ្ងៃទី..០៥..ខែ..០៦..ឆ្នាំ២០១៧

# សេចក្តីណែនាំ
## ស្តីពី
## ការធ្វើប្រតិភូកម្មការចុះបញ្ជីទោចក្រយានយន្តទៅរដ្ឋបាលថ្នាក់ក្រោមជាតិ

ក្នុងគោលបំណងអនុវត្តអនុក្រឹត្យ លេខ១៨ អនក្រ.បក ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការបង្កើតយន្តការច្រកចេញចូលតែមួយសម្រាប់ការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ និងស្របតាមប្រកាសចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៤ ស្តីពីការធ្វើប្រតិភូកម្មអំណាចរដ្ឋបាលកណ្តាលពីក្រសួងសាធារណការ និងដឹកជញ្ជូនជូនដល់រដ្ឋបាលខណ្ឌនៃរាជធានីភ្នំពេញ ក្នុងការចុះបញ្ជីទោចក្រយានយន្ត ក្រសួងសាធារណការ និងដឹកជញ្ជូន សូមធ្វើការណែនាំដូចខាងក្រោមៈ

១. បញ្ឈប់ការចុះបញ្ជីទោចក្រយានយន្តដើម្បីផ្តល់បណ្ណសម្គាល់ និងផ្លាកលេខ ការផ្ទេរកម្មសិទ្ធ ទុតិយតាតតិយតាបណ្ណសម្គាល់ និងផ្លាកលេខទោចក្រយានយន្ត នៅមន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានី-ខេត្តទាំងស្រុង។ ក្នុងអត្ថន័យនេះ ការិយាល័យច្រកចេញចូលតែមួយរបស់រដ្ឋបាលខណ្ឌនៃរាជធានីភ្នំពេញ និងរដ្ឋបាលថ្នាក់ក្រោមជាតិនៅទូទាំងប្រទេស ត្រូវសាកល្បងអនុវត្តមុខងារទាំងនេះតាមប្រព័ន្ធស្វ័យប្រវត្តិកម្មរបស់ក្រសួងជំនួសវិញ ជូនប្រជាពលរដ្ឋដែលស្ថិតក្នុងដែនសមត្ថកិច្ចខ្លួន។ ចំពោះការិយាល័យច្រកចេញចូលនៅតាមបណ្តារាជធានី-ខេត្តណាដែលមិនទាន់ត្រៀមលក្ខណៈរួចរាល់ និងមិនទាន់ដំណើរការ មន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានី-ខេត្ត ត្រូវបន្តផ្តល់សេវាក្នុងការចុះបញ្ជីទោចក្រយានយន្តដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

២. មន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានី-ខេត្ត ត្រូវពិនិត្យ តាមដាន និងគ្រប់គ្រងការអនុវត្តផ្តល់សេវាក្នុងការចុះបញ្ជីទោចក្រយានយន្តរបស់ការិយាល័យច្រកចេញចូលតែមួយ និងក្នុងករណីចាំបាច់ ត្រូវធ្វើការណែនាំក្នុងការអនុវត្ត និងផ្តល់នូវការគាំទ្រ រួមទាំងការបណ្តុះបណ្តាលបច្ចេកទេសដល់ការិយាល័យច្រកចេញចូលតែមួយ។

មហាវិថីព្រះនរោត្តម កែងផ្លូវលេខ១០៦, សង្កាត់វត្តភ្នំ, ខណ្ឌដូនពេញ, រាជធានីភ្នំពេញ, កម្ពុជា
Corner Norodom Blvd, St. 106, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, Cambodia
ទូរស័ព្ទ/ទូរសារៈ (៨៥៥) ០២៣ ៤២៦ ៦៤០ (៨៥៥) ០២៣ ៤២៧ ៨៦២
Tel/Fax: (855) 23 426 640, (855) 23 427 862 www.mpwt.gov.kh

ទទួលបានសេចក្តីណែនាំខាងលើ អគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវគោក អគ្គលេខាធិការដ្ឋានគ.ជ.អ.ប នៃក្រសួងមហាផ្ទៃ នាយកដ្ឋានដឹកជញ្ជូនផ្លូវគោក មន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានី-ខេត្ត និង ការិយាល័យច្រកចេញចូលតែមួយនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវអនុវត្តឱ្យបានត្រឹមត្រូវ និងមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន**

**ស៊ុន ចាន់ថុល**

**ចម្លងជូន:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រចាំការ
- គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ
- គ្រប់សាលារាជធានី-ខេត្ត "ដើម្បីជូនជ្រាប"
- អគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវគោក "ដើម្បីអនុវត្ត"
- អគ្គលេខាធិការដ្ឋានគ.ជ.អ.ប នៃក្រសួងមហាផ្ទៃ "ដើម្បីជូនជ្រាប"
- នាយកដ្ឋានដឹកជញ្ជូនផ្លូវគោក "ដើម្បីអនុវត្ត"
- គ្រប់មន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានី-ខេត្ត "ដើម្បីអនុវត្ត"
- ការិយាល័យច្រកចេញចូលតែមួយ នៃរដ្ឋបាលថ្នាក់ក្រោមជាតិ "ដើម្បីអនុវត្ត"
- ឯកសារ កាលប្បវត្តិ